# ក្នុងការធ្វើដំណើរឆ្ពោះទៅមុខ ត្រូវងាកមើលក្រោយ

ក្រោយពេលដែលជម្លោះ អំពើហិង្សា និងការរំលោភទៅលើសិទ្ធិមនុស្សស្ងប់ស្ងាត់ទៅ មនុស្សគ្រប់គ្នាតែងតែចង់ឲ្យអ្នកដែលស្រលាញ់សន្តិភាពឱបក្រសោបយកនូវគំនិតនៃការផ្សះផ្សាបង្រួបបង្រួមជាតិ ។ ទំនោរបែបនេះបានក្លាយទៅជាការទាស់ទែងខ្វែងគំនិតគ្នានៅក្នុងតំបន់មួយចំនួន មិនមែនមកអំពីមូលហេតុនៃអត្ថន័យពិតប្រាកដនៃសម្តីខាងលើទេ ប៉ុន្តែដោយសារវាត្រូវបានប្រើប្រាស់ដោយជនដែលមានគំនិតមិនល្អនិងអតីតកាលដ៏ខ្មៅងងឹត ។ មេដឹកនាំនៃរបបហិង្សាយោធានៅអាមេរិកឡាទីន និងអាមេរិកកណ្តាលបានចាត់ទុកការផ្សះផ្សាបង្រួបបង្រួមជាតិជា «ការអនុគ្រោះនិងការបំភ្លេចអតីតកាល» ។ ការបង្ខំឲ្យបំភ្លេចចោលអតីតកាលដែលក្លែងបន្លំជាការផ្សះផ្សាបង្រួបបង្រួមជាតិនេះប្រាកដណាស់គួរតែត្រូវបដិសេធចោលដោយជនណាដែលព្យាយាមកសាងនូវសន្តិភាពយូរអង្វែង ។


គ្រួសារប្រជាជនមូលដ្ឋាននៅក្នុងតំបន់២៥ ឆ្នាំ១៩៧៧

ផ្ទុយទៅវិញ ការយល់ដឹងដ៏ត្រឹមត្រូវនិងការអនុវត្តនូវទ្រឹស្តីការផ្សះផ្សាបង្រួបបង្រួមជាតិគឺមានសារសំខាន់ណាស់ចំពោះការប្រឈមមុខនឹងអតីតកាលបែកបាក់និងអំពើហិង្សា ។ ការផ្សះផ្សាបង្រួបបង្រួមជាតិពិតប្រាកដតម្រូវឲ្យមានការត្រួតពិនិត្យដោយស្មោះត្រង់ទៅលើប្រវត្តិសាស្ត្រ ដើម្បីលាតត្រដាងនិងកត់សម្គាល់ឧក្រិដ្ឋកម្មពីអតីតកាល ។ ជំនួសឲ្យការបំបិទមាត់ជនរងគ្រោះមិនឲ្យនិយាយ និងការមិនគិតគូរចំពោះជនរងគ្រោះ យើងត្រូវធ្វើយ៉ាងណាឲ្យសំឡេងរបស់ជនរងគ្រោះត្រូវគេស្តាប់ ហើយការឈឺចាប់របស់ជនរងគ្រោះត្រូវគេដឹងឮ ។

ប្រធានាធិបតីថ្មីរបស់ប្រទេសអាហ្សង់ទីនឈ្មោះ នេស្តូ ឌីចនេ្ន បានបញ្ជាក់យ៉ាងក្បោះក្បាយនូវចំណុចនេះនៅក្នុងពិធីឡើងកាន់អំណាចរបស់លោកថា គាត់មានគោលបំណង «ដឹកនាំដោយគ្មានការគុំកួន ប៉ុន្តែដើម្បីការចងចាំ» ។ យុត្តិធម៌និងការទទួលខុសត្រូវគឺជាធាតុចម្បងនៃការផ្សះផ្សាបង្រួបបង្រួមជាតិពិតប្រាកដ ។ ការផ្សះរបួសឡើងវិញគួរតែត្រូវបានផ្តល់ទៅឲ្យជនរងគ្រោះ មិនមែនក្នុងគោលបំណងធ្វើជាសំណងសម្រាប់ការបាត់បង់និងទុក្ខវេទនាដែលជនរងគ្រោះបានទទួលនោះទេ ប៉ុន្តែដើម្បីបង្ហាញថាមនុស្សជាតិមិនអាចទទួលយកនូវអំពើហិង្សាបានតទៅទៀតឡើយ ។

បើគ្មានការពិត យុត្តិធម៌ និងតម្លៃតបស្នង ជនរងគ្រោះនិង

សង្គម ជនរងគ្រោះនឹងយល់ថារបបថ្មីកំពុងតែធ្វើអ្វីដែលប្រាសចាកទៅនឹងគោលបំណងរបស់ខ្លួនគេហើយ ។ ជនរងគ្រោះនៅតែជាជនរងគ្រោះដដែល ។ ដោយសារការទទួលរងនូវឋានៈជាជនរងគ្រោះមិនឈប់ឈរដូចនេះ ជនរងគ្រោះទាំងនេះងាយស្រួលនឹងធ្លាក់ទៅក្រោមការគាបសង្កត់របស់មេដឹកនាំដែលព្យាយាមកេងប្រយោជន៍ពីកំហឹងនិងភាពមិនកក់ក្តៅរបស់ជនរងគ្រោះ ។ ទាំងប្រទេសរ៉្វាន់ដានិងអតីតប្រទេសយូហ្គោស្លាវី បានបង្ហាញនូវឥទ្ធិពលដ៏ឈឺចាប់នៃការអនុញ្ញាតឲ្យអារម្មណ៍ទុក្ខសោកអំពីប្រវត្តិសាស្ត្រស្ថិតក្រោមការកែច្នៃរបស់អ្នកនយោបាយស្នេហាជាតិនិងប្រកាន់ពូជសាសន៍ ។ ដោយគ្មានការផ្សះផ្សាបង្រួបបង្រួមជាតិដ៏ពិតប្រាកដ ជនរងគ្រោះកាលពីម្សិលមិញអាចនឹងក្លាយទៅជាជនដៃដល់នៅថ្ងៃនេះយ៉ាងងាយស្រួលបំផុត ។ ការសុំទោសនិងការទទួលកំហុសក្នុងពេលថ្មីៗនេះរបស់លោក ប៊ីលហ្សាណា ផ្លាវស៊ិក អតីតមេដឹកនាំម្នាក់របស់ជនជាតិស៊ែប៊ី ក្នុងប្រទេសបូស្នៀ នៅក្នុងតុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតប្រទេសយូហ្គោស្លាវី អាចដើរតួនាទីយ៉ាងសំខាន់នៅក្នុងការបំបាត់ចោលនូវការយល់ឃើញគ្មានហេតុផលដែលថាជនជាតិស៊ែប៊ី គ្រាន់ជាជនរងគ្រោះតែប៉ុណ្ណោះ ហើយជនជាតិនេះមិនទទួលខុសត្រូវចំពោះជម្លោះបច្ចុប្បន្នឡើយ ។ ដោយទទួលនូវការដាក់ទណ្ឌកម្មនិងបញ្ជាក់នូវភាពសោកស្តាយ ផ្លាវស៊ិក បានបើកទូលាយឲ្យមានការផ្សះផ្សាបង្រួបបង្រួមជាតិពិតប្រាកដនៅក្នុងតំបន់ ។ ការផ្សះផ្សាបង្រួបបង្រួមជាតិតម្រូវឲ្យមានការផ្លាស់ប្តូរនូវគំនិតចាស់ ។ នៅក្នុងប្រទេសដែលមេដឹកនាំពុករលួយបានបង្កើតនូវស្ថាប័នហិង្សាចាក់ឫសគល់ទៅក្នុងសង្គមសន្តិភាពយូរអង្វែងនឹងមិនលេចចេញឡើយ លុះត្រាណាតែស្ថាប័ននគរបាល យោធា តុលាការ និងអង្គភាពផ្សេងៗទៀតនៃរដ្ឋាភិបាល ឆ្លងកាត់នូវកំណែទម្រង់ជាមូលដ្ឋានគ្រឹះមួយ ។ ដើម្បីឲ្យល្បាយដែលងាយនឹងផ្ទុះជាសង្គ្រាមរវាងជនជាតិនិងសាសនាផ្សេងៗគ្នានៅក្នុងប្រទេសអ៊ីរ៉ាក់ក្រោយសង្គ្រាមរួមផ្គុំគ្នាជាធុងមួយបាន លុះត្រាណាមានការបង្កើតឡើងនូវស្ថាប័នជាតិដែលអាចលុបបំបាត់ចោលទាំងស្រុងនូវការគាបសង្កត់និងការបែងចែកនិយមនៃអតីតកាល ។

ជាការពិតណាស់ គម្លាតដ៏ធំផ្នែកទ្រព្យសម្បត្តិនិងអំណាចមានឫសគល់ចេញមកអំពីជម្លោះ ។ ជនដែលបន្តក្តោបក្តាប់នូវអភ័យឯកសិទ្ធិលើសលប់ក្រោយពេលមានជម្លោះ តែងតែមិនយល់ថា ការផ្សះផ្សាបង្រួបបង្រួមជាតិមិនឋិតថេរបានទេនៅក្នុងវិសមភាពនៃសិទ្ធិដែលចេះតែបន្ត ។

គ្មានអ្វីដែលអាចអត់ឱនឲ្យមេដឹកនាំដែលមិនខ្វាយខ្វល់ចំពោះលទ្ធផលនៃទង្វើរបស់ខ្លួនទេ ។ នយោបាយគ្មានឧត្តមគតិនិងមិនបម្រើសង្គមរបស់ប្រធានាធិបតី រ៉ូប៊ើត មូហ្គាប៊ី នៅក្នុងប្រទេសហ្ស៊ីមបាវេ នឹងត្រូវទទួលយកបានតិចជាងនេះ ប្រសិនបើបន្ទាប់ពីទទួលបានឯករាជ្យជនជាតិស្បែកសប្រកាន់យកទ្រឹស្តីទំនើបជាងបច្ចុប្បន្នចំពោះការបែងចែកទ្រព្យសម្បត្តិដ៏ស្មើភាពគ្នាមួយ ។

ក្នុងករណីនេះ គួរឲ្យអស្ចារ្យណាស់ដែលប្រទេសអាហ្វ្រិកខាងត្បូងបានធ្វើដំណើរឆ្ពោះទៅមុខយ៉ាងឆ្ងាយក្នុងការកសាង "ជាតិឥន្ទធនូ" (ប្រទេសដែលលាយជាតិសាសន៍ច្រើន) មួយដែលប្តូរផ្តាច់ចំពោះការផ្សះផ្សាបង្រួបបង្រួមជាតិ ។ ប៉ុន្តែប្រទេសហ្ស៊ីមបាវេគួរតែក្លាយទៅជាមេរៀនមួយសម្រាប់ជនជាតិស្បែកសដែលនៅតែបន្តគ្រប់គ្រងទ្រព្យសម្បត្តិភាគច្រើនរបស់ប្រទេសអាហ្វ្រិកខាងត្បូង ។ ការផ្សះផ្សាបង្រួបបង្រួមជាតិពិតប្រាកដតម្រូវឲ្យមានការលះបង់ខ្ពស់ ដែលរួមទាំងការព្យាយាមលុបបំបាត់ចោលនូវភាពមិនស្មើគ្នាដែលចេះតែបន្តកើតមាននៅពេលដែលការប្រយុទ្ធគ្នាត្រូវបានបញ្ចប់ ។

ការផ្សះផ្សាបង្រួបបង្រួមជាតិយូរអង្វែងតម្រូវឲ្យមានកំណែទម្រង់ច្បាប់ នយោបាយ និងសេដ្ឋកិច្ច ជាទ្រង់ទ្រាយធំ ។ ប៉ុន្តែធ្វើដូច្នេះបានអាស្រ័យទៅលើសកម្មភាពរបស់មេដឹកនាំដែលមានតួនាទីសំខាន់នៅក្នុងជម្លោះ ។ មេដឹកនាំដែលមានចក្ខុវិស័យខ្ពស់ដូចជា នែលសុន មែនដឺឡា និង អង់សាន ស៊ូជី បានបញ្ជាក់នូវចិត្តទូលំទូលាយ ទោះជាមេដឹកនាំទាំងពីរនេះមានឱកាសទាមទារនូវការសងសឹកវិញក៏ដោយ ។ ប៉ុន្តែការកើនឡើងនៃភាពស្និទ្ធស្នាលគ្នានឹងមិននាំទៅរកការផ្សះផ្សាបង្រួបបង្រួមជាតិទេ លុះត្រាណាតែចិត្តសប្បុរសនេះត្រូវបានតបស្នងវិញដោយការព្យាយាមព្យាបាលរបួសចាស់នៃជម្លោះដោយជនដែលបានប្រព្រឹត្ត ។

**អាឡិច បូរេន និង ប៉ូល ម៉ាន់ហ្វ៊ីលអ៊ីត**